# ពុទ្ធភាសិត

០០១ ទោសរបស់អ្នកដទៃ បុគ្គលមើលឃើញងាយ ឯទោសរបស់ខ្លួនវិញ បុគ្គលមើលឃើញដោយកម្រ (សុទស្សំ វជ្ជំ មញ្ញេសំ អត្តនោ បន ទុទ្ទសំ)

០០២ មនុស្សខ្ជិលតែងមិនបានប្រទះផ្លូវនៃប្រាជ្ញា (បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ)

០០៣ សេចក្តីលោភជាអន្តរាយដល់កុសលធម៌ទាំងឡាយ (លោភោ ធម្មានំ បរិបន្ថោ)

០០៤ ចិត្តមិនជាប់ជំពាក់ ទើបធ្វើទានកើត (អលោភោ ទានហេតុ)

០០៥ មនុស្សឥតប្រាជ្ញាតែងណែនាំតែការដែលមិនគួរណែនាំ (អនយំ នយតិ ទុម្មេធោ)

០០៦ អ្នកមានប្រាជ្ញាតែងមិនណែនាំការដែលមិនគួរណែនាំ (នានយំ នយតិ ធីរោ)

០០៧ ពាក្យជាសុភាសិតមិនមានក្នុងមនុស្សប្រទូស្តរាយ (នត្ថិ ទុដ្ឋេ សុភាសិតំ)

០០៨ បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការណាៗគួរប្រឹងព្យាយាមក្នុងទីនោះ ដោយប្រការនោះៗ (យថា យថា យត្ថ លភេថ អត្ថំ តថា តថា តត្ថ បរក្កមេ)

០០៩ បុគ្គលមិនត្រូវលះបង់ខ្លួនចោលឡើយ (អត្តានំ ន បរិច្ចជេ)

០១០ ការសមាគមនឹងពួកពាល តែងនាំមកនូវសេចក្តីទុក្ខ (ទុក្ខោ ពាលេហិ សង្គមោ)

០១១ មិនគួរធ្វើបាប ព្រោះហេតុតែស៊ីទេ (ន ឃាសហេតូបិ ករេយ្យ បាបំ)

០១២ ពិចារណាមុនហើយសឹមធ្វើ ប្រសើរជាង (និសម្ម ករណំ សេយ្យោ)

០១៣ ពាក្យពិត ជាវាចាមិនចេះស្លាប់ (សច្ចំ វេ អមតា វាចា)

០១៤ កូនក្រោធឡើងកាលណាអាចសម្លាប់ម្តាយបេស់ខ្លួនក៏បាន (ហន្តិ កុទ្ធោ សមាតរំ)

០១៥ អ្នកឱ្យរបស់ខ្ពង់ខ្ពស់ រមែងបានរបស់ខ្ពង់ខ្ពស់មកវិញ (អគ្គស្ស ទាតា លភតេ បុនគ្គំ)

០១៦ កិត្តិយសរមែងមិនលះបង់បុគ្គលដែលឋិតនៅក្នុងធម៌ (ធម្មេ ឋិតំ ន វិជហាតិ កិត្តិ)

០១៧ តាំងពីកាលណាៗមក ពៀរមិនដែលរំងាប់បានដោយពៀរឡើយ ពៀរតែងរំងាប់បានដោយការមិនចងពៀរ គឺមេត្តា នេះជាធម៌នៃបោរាណបណ្ឌិត (ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ)

០១៨ អ្នកឈ្នះដេកសោយពំនៀរ អ្នកចាញ់ដេកកើតទុក្ខ អ្នកមានចិត្តស្ងប់ដេកជាសុខ (ព្រោះហេតុនេះ បុគ្គលអ្នកត្រូវការឱ្យជីវិតមានសន្តិភាព)គប្បីលះបង់ចោលនូវជំនះនិងចំណាញ់ឱ្យអស់ (ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោឧបសន្តោ សុខំ សេតិ ហិត្វាជយបរាជយំ)

០១៩ អ្នកប្រាជ្ញតែងរក្សាទុកនូវសេចក្ដីមិនប្រមាទ ដូចជាបុគ្គលរក្សាទ្រព្យដ៏ប្រសើរ (អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ)

០២០ បណ្ឌិតទាំងឡាយតែងសរសើរសេចក្ដីមិនប្រមាទ (អប្បមាទំ បសំ សន្តិ)

០២១ បណ្ឌិតទាំងឡាយតែងរីករាយក្នុងសេចក្ដីមិនប្រមាទ (អប្បមាទេ បមោទន្តិ)

០២២ ស្ត្រីជាមន្ទិលរបស់ព្រហ្មចារ្យ (ឥត្ថី មលំ ព្រហ្មចរិយស្ស)

០២៣ អំណាច ជាធំក្នុងលោក (វសោ ឥស្សរិយំ លោកេ)

០២៤ សេចក្ដីស្រឡាញ់ស្មើដោយខ្លួនមិនមាន (នត្ថិ អត្តសមំ បេមំ)

០២៥ ធម៌របស់សប្បុរសទាំងឡាយ បុគ្គលប្រព្រឹត្តតាមបានដោយកម្រ (សតំ ធម្មោ ទុរន្វយោ)

០២៦ ការសន្សំនូវបាបតែងនាំមកនូវសេចក្ដីទុក្ខ (ទុក្ខោ បាបស្ស ឧច្ចយោ)

០២៧ ការសន្សំនូវបុណ្យតែងនាំមកនូវសេចក្ដីសុខ (សុខោ បុញ្ញស្ស ឧច្ចយោ)

០២៨ បាបមិនមានដល់បុគ្គលដែលមិនធ្វើ (នត្ថិ បាបំ អកុព្វតោ)

០២៩ កលិ គឺទោសកំហុសស្មើដោយទោសៈមិនមានឡើយ (នត្ថិ ទោសសមោ កលិ)

០៣០ សេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធជារបស់ចំពោះខ្លួន អ្នកដទៃនឹងញុំាងអ្នកដទៃឱ្យបរិសុទ្ធមិនបានឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ)

០៣១ ការមិនធ្វើបាបទាំងឡាយតែងនាំមកនូវសេចក្ដីសុខ (បាបានំ អករណំ សុខំ)

០៣២ អ្នកបរិភោគតែម្នាក់ឯង តែងមិនបានសេចក្ដីសុខទេ (នេកាសី លភតេ សុខំ)

០៣៣ ត្រូវឈ្នះសេចក្ដីក្រោធដោយសេចក្ដីមិនក្រោធ (អក្កោធេន ជិនេ កោធំ)

០៣៤ ត្រូវឈ្នះសេចក្ដីអាក្រក់ដោយសេចក្ដីល្អ (អសាធុំ សាធុនា ជិនេ)

០៣៥ ត្រូវឈ្នះសេចក្ដីកំណាញ់ដោយការធ្វើទាន (ជិនេ កទរិយំ ទានេន)

០៣៦ ត្រូវឈ្នះអ្នកនិយាយពាក្យឡេះឡោះដោយពាក្យពិត (សច្ចេនាលិកវាទិនំ ជិនេ)

០៣៧ ការយកឈ្នះខ្លួនឯងបានជាការប្រសើរណាស់ (អត្តា ហវេ ជិតំ សេយ្យោ)

០៣៨ ខ្លួនហ្នឹងហើយដែលបុគ្គលទូន្មានបានដោយកម្រ (អត្តា ហិ កិរ ទុទ្ទមោ)

០៣៩ បណ្ឌិតទាំងឡាយតែងមិនសំដែងអាការខ្ពស់ទាប (ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ)

០៤០ មិត្តអាមាត្យទុកជាទិសខាងឆ្វេង (មិត្តាមច្ចា ច ឧត្តរា)

០៤១ បណ្ដាផ្លូវទាំងឡាយ ផ្លូវមានអង្គ៨ជាផ្លូវក្សេមជាហេតុឱ្យដល់នូវអមតធម៌ (អដ្ឋង្គិកោ ច មគ្គានំ ខេមំអមតគាមិនំ)

០៤២ សត្វលោកតែងប្រព្រឹត្តទៅតាមកម្ម (កម្មុនា វត្តតិ លោកេ)

០៤៣ បុគ្គលគប្បីដឹងច្បាស់នូវបញ្ញា ដោយសារការសន្ទនា (សាកច្ឆាយ បញ្ញា វេទិតព្វា)

០៤៤ បុគ្គលគប្បីដឹងច្បាស់នូវសីល ដោយសារការនៅរួបរួមគ្នា (សំវាសេន សីលំ វេទិតព្វំ)

០៤៥ កិរិយាអត់ធន់ជាគ្រឿងប្រដាប់របស់អ្នកប្រាជ្ញ (ខន្តិ ធីរស្ស លង្ការា)

០៤៦ បុគ្គលសាបព្រោះពូជយ៉ាងណា រមែងបានទទួលផលយ៉ាងនោះ
(យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ)

០៤៧ អ្នកធ្វើហេតុល្អតែងបានទទួលផលល្អ អ្នកធ្វើហេតុអាក្រក់តែងបានទទួលផលអាក្រក់
(កល្យាណការី កល្យាណំ បាបការី ច បាបកំ)

០៤៨ ស្តាប់ដោយល្អ ទើបបានប្រាជ្ញា (សុស្សូសំ លភតេ បញ្ញំ)

០៤៩ ការមិនបៀតបៀនគ្នាជាសុខក្នុងលោក (អព្យាបជ្ឈំ សុខំ លោកេ)

០៥០ ការស្អាតគប្បីដឹងច្បាស់ដោយការងារ (សំវោហារេន សោចេយ្យំ វេទិតព្វំ)

០៥១ បុគ្គលគប្បីដឹងច្បាស់នូវកម្លាំងចិត្តក្នុងវេលាមានអន្តរាយ (អាបទាសុ ថាមោ វេទិតព្វោ)

០៥២ ខ្លួនហ្នឹងហើយ ជាទីពឹងរបស់ខ្លួន (អត្តា ហិ អត្តនោ នាថោ)

០៥៣ អ្នកណាជាមនុស្សពាល តែដឹងខ្លួនថាពាល អ្នកនោះអាចត្រឡប់ជាបណ្ឌិតវិញបានខ្លះ
ដោយហេតុដែលដឹងខ្លួននោះ (យោ ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ)

០៥៤ មិនត្រូវសូមរបស់ដែលជាទីស្រឡាញ់ពេញចិត្តរបស់គេ (នតំ យាចេ អស្ស បិយំ ជិគីសេ)

០៥៥ មនុស្សដែលគេស្អប់ ក៏ព្រោះតែសូមហួសពេក (ទេស្សោ ច ហោតិ អតិយាចនាយ)

០៥៦ សូមមិនជាទីពេញចិត្តនៃអ្នកឱ្យ (យាចនោ អប្បិយោ ហោតិ)

០៥៧ កម្មបែងចែកពពួកសត្វឱ្យមានថោកទាបនិងប្រសើរផ្សេងៗគ្នា (កម្មំ សត្តេ វិភជតិ យទិទំ
ហីនប្បណីតតាយ)

០៥៨ ការសមាគមនឹងសប្បុរសតែងនាំមកនូវសេចក្តីសុខមែនពិត (សុខោ ហវេ សប្បុរិសេន សង្គមោ)

០៥៩ ទាំងអ្នកមាន ទាំងអ្នកក្រសុទ្ធតែមានសេចក្តីស្លាប់ជាទីទៅខាងមុខ (អឌ្ឍា ចេវ ទលិទ្ទា ច
សព្វេ មច្ចុបរាយនា)

០៦០ សម្លាញ់ជាមិត្តរបស់អ្នកមានធុរៈកើតឡើងរឿយៗ (សហាយោ អត្ថជាតស្ស ហោតិ
មិត្តំ បុនប្បុនំ)

០៦១ សមណៈទាំងឡាយមិនមែនជាសឹកសត្រូវក្នុងលោក (សមណី ធ អរណា លោកេ)

០៦២ មាតាបិតាឈ្មោះថាជាព្រហ្មរបស់កូន (ព្រហ្មាតិ មាតាបិតរោ)

០៦៣ មន្តទាំងឡាយ មានការមិនទន្ទេញស្វាធ្យាយជាមន្ទិល (អសជ្ឈាយមលា មន្តា)

០៦៤ ផ្ទះមានការមិនព្យាយាមជួសជុលជាដើម ជាមន្ទិល (អនុដ្ឋានមលា ឃរា)

០៦៥ សេចក្តីខ្ជិលជាមន្ទិលដល់ពណ៌សម្បុរ (មលំ វណ្ណស្ស កោសជ្ជំ)

០៦៦ ជនមិនប្រមាទឈ្មោះថា មិនចេះស្លាប់ (អប្បមត្តា ន មិយ្យន្តិ)

០៦៧ អំពើអាក្រក់ មិនធ្វើសោះឡើយប្រសើរជាង (អកតំ ទុក្កដំ សេយ្យោ)

០៦៨ អំពើអាក្រក់តែងតាមដុតរោលរាលក្នុងវេលាក្រោយ (បច្ឆា តប្បតិ ទុក្កដំ)

០៦៩ បុគ្គលធ្វើតែអំពើល្អ ទើបប្រសើរ (កតញ្ច សុកតំ សេយ្យោ)

០៧០ បើនឹងធ្វើការអ្វីៗត្រូវធ្វើការនោះឱ្យមែនទែន (កយិរា ចេ កយិរា ថនំ)

០៧១ សេចក្តីសង្រួមក្នុងទីទាំងពួង ជាការញ៉ាំងប្រយោជន៍ឱ្យសម្រេច (សាធុ សព្វត្ថ សំវរោ)

០៧២ បុណ្យពួកចោរលួចយកទៅបានដោយកម្រ (បុញ្ញំ ចោរេហិ ទូហរំ)

០៧៣ បុគ្គលបានសេចក្តីក្តៅក្រហាយ ព្រោះបញ្ចេញវាចាអាក្រក់ (មុត្តា តបតិ បាបិកំ)

០៧៤ ចូរអ្នកស្តាប់ធម៌ទាំងរបស់អសប្បុរស ទាំងរបស់សប្បុរស (សុណោហិ ធម្មំ អសតំ សតញ្ច)

០៧៥ ចូរលះបង់អសប្បុរសចេញ តែកុំលះបង់សប្បុរសឡើយ (ហិត្វា អសន្តេ ន ជហាហិ សន្តេ)

០៧៦ ពួកពហុស្សូត (អ្នកចេះដឹងច្រើន)មានប្រាជ្ញាពិចារណាជាកម្លាំង (បដិសង្ខានពលា ពហុស្សុតា)

០៧៧ ភរិយាល្អប្រព្រឹត្តទៅតាមអំណាចសេចក្តីគាប់ចិត្តរបស់ភស្តា (ភត្តុ ឆន្ទវសានុគា)

០៧៨ អ្នកដែលមានសេចក្តីក្រោធគ្របសង្កត់ហើយរមែងលះបង់នូវការកុសល (កោធាភិភូតោ កុសលំ ជហាតិ)

០៧៩ ទោសៈមានសេចក្តីក្រោធជាសមុដ្ឋាន (ទោសោ កោធសមុដ្ឋានោ)

០៨០ អ្នកប្រព្រឹត្តធម៌រមែងមិនទៅកាន់ទុគ្គតិភព (នទុគ្គតឹ គច្ឆតិ ធម្មចារី)

០៨១ អ្នកខំខ្នះខ្នែងតែងស្វែងរកទ្រព្យបាន (ឧដ្ឋាតា វិន្ទតេ ធនំ)

០៨២ បុគ្គលលុះដល់នូវកេរ្តិ៍ឈ្មោះ ព្រោះពាក្យសត់ (សច្ចេន កិត្តឹ បប្បោតិ)

០៨៣ អ្នកដែលគេសូម កាលបើមិនឱ្យក៏មិនជាទីស្រឡាញ់ពេញ ចិត្តរបស់ស្នូម (យាចំ អទទមប្បិយោ)

០៨៤ វាចាប្រាកដស្មើដោយចិត្ត (ហទយស្ស សទិសី វាចា)

០៨៥ ភ្លើងស្មើដោយរាគៈមិនមានឡើយ (នត្ថិ រាគសមោ អគ្គិ)

០៨៦ សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឱ្យ (មច្ឆេរំ ទទតោ មលំ)

០៨៧ អវិជ្ជា គឺសេចក្តីល្ងង់ខ្លៅ ជាមន្ទិលយ៉ាងក្រៃលែង (អវិជ្ជា បរមំ មលំ)

០៨៨ ការចាប់ស្មើដោយទោសៈមិនមានឡើយ (នត្ថិ ទោសសមោ គហោ)

០៨៩ សង្ខារទាំងឡាយមិនទៀង (អនិច្ចា វត សង្ខារា)

០៩០ ភាជដីទាំងពួងមានការបែកធ្លាយទៅជាទីបំផុតយ៉ាងណា ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ (សព្វំ ភេទបរិយន្តំ ឯវំ មច្ចានជីវតំ)

០៩១ ការមិនមានរោគជាលាភយ៉ាងក្រៃលែង (អរោគ្យា បរមា លាភា)

០៩២ កើតជាបុរសត្រូវតែព្យាយាមត្រាតែសម្រេចប្រយោជន៍ (វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា)

០៩៣ ក្នុងការប្រឹក្សា គេត្រូវការមនុស្សដែលមិននិយាយប៉ប៉ាច់ប៉ប៉ោច (មន្តីសុ អកុតូហលំ)

០៩៤ ការដែលមិនល្អផង មិនមានប្រយោជន៍ដល់ខ្លួនផង បុគ្គលធ្វើបានងាយ
(សុករានិ អសាធូនិ អត្តនោអហិតានិ ច)

០៩៥ ការឯណាមានប្រយោជន៏ផង ល្អផង នេះឯងបុគ្គលធ្វើបានដោយកម្រក្រៃពេក
(យំ វេ ហិតញ្ច សាធុញ្ច តំវេ បរម ទុក្ករំ)

០៩៦ មនុស្សដែលមិនត្រូវគេនិន្ទា មិនមានក្នុងលោក (នត្ថិ លោកេ អនិន្ទិតោ)

០៩៧ ឈ្មោះថាការស្ទាត់កំបាំង មិនមានក្នុងលោក (នត្ថិ លោកេ រហោ នាម)

០៩៨ បុគ្គលមិនត្រូវប្រគល់ខ្លួនទាំងស្រុងដល់អ្នកដទៃទេ (អត្តានំ ន ទទេ បោសោ)

០៩៩ អ្នកដែលប្រារព្ធសេចក្តីព្យាយាមខ្ជាប់ខ្ជួន ទុកជាមានជីវិតរស់នៅ
ត្រឹមមួយថ្ងៃ ក៏ប្រសើរជាង (ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ)

០១០០ ការងារឯណាមួយដែលធូររាររមែងមិនមានផលច្រើនទេ ។
(យំកិញ្ចិ សិថិលំ កម្មំ នតំហោតិ មហប្ផលំ)